En5

En 5

World Vision
Cambodia

Participatory of Residue Management

# ការចូលរួមគ្រប់គ្រងសំណល់ផ្សេងៗ

## ឧបត្ថម្ភដោយ

### កម្មវិធីអភិវឌ្ឍន៍តាមតំបន់ស្រុក បាត់ដំបង នៃ

## អង្គការទស្សនៈពិភពលោក កម្ពុជា




រៀបចំដោយបុគ្គលិកមន្ទីរបរិស្ថានខេត្តបាត់ដំបង រួមជាមួយ

លោក ហ្គដិន អេវើរ ( Gordon Ewers-AVI) ជំនួយការស្ម័គ្រចិត្តអូស្ត្រាលី

# សេចក្តីផ្តើម

មន្ទីរបរិស្ថានខេត្តបាត់ដំបង បានចងក្រងសៀវភៅនេះឡើង ដោយមានការចូលរួមឧបត្ថម្ភ ពី
កម្មវិធីអភិវឌ្ឍន៍តាមដំបន់ស្រុកបាត់បង នៃ អង្គការទស្សនៈពិភពលោក កម្ពុជា
ដើម្បីធ្វើអោយប្រជាពលរដ្ឋយល់ដឹងនូវបញ្ហាទាំងឡាយដែលកើតមានអំពីសំណល់ផ្សេងៗ ។

សៀវភៅនេះមានសារៈសំខាន់ណាស់សំរាប់ប្រជាពលរដ្ឋយល់ដឹងអំពីបញ្ហាកើតឡើង ដោយសារសំណល់ផ្សេងៗ ពីព្រោះការបញ្ចេញចោលសំណល់គ្រប់ប្រភេទរបស់ប្រជាពលរដ្ឋ បណ្តាលអោយមានការ បំពុល ហើយការបំពុលនោះ អាចធ្វើអោយប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ទៅលើសុខភាពមនុស្ស និង បរិស្ថាន ។

ប្រជាពលរដ្ឋទូទៅ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់គ្រប់ប្រភេទរបស់ខ្លួន ហើយនិងការបោះចោលសំណល់ផ្សេងៗទាំងនោះអោយបានត្រឹមត្រូវ ។

សៀវភៅនេះ និង ជួយអោយលោកអ្នកបានយល់ដឹងអំពី :

- សំណល់សំរាមជាអ្វី
- ប្លាស្ទិកជាអ្វី
- ការកាត់បន្ថយសំណល់ផ្សេងៗ
- ការបំពុលជាអ្វី
- និងការបោះចោលសំណល់ផ្សេងៗ

សូមថ្លែងអំណរគុណដល់លោកអ្នក ដែលយកចិត្តទុកដាក់ អានសៀវភៅនេះ ហើយសូមមេត្តា ជួយផ្សព្វផ្សាយពត៌មានសំខាន់ៗក្នុងសៀវភៅនេះបន្តជូនដល់អ្នកដទៃទៀត ដូចនេះហើយយើងគ្រប់រូប អាចទទួលបាននូវលទ្ធផលល្អប្រសើរអំពីការសំអាត និង បរិស្ថានល្អ គ្រប់ៗគ្នា ។

# តើការបំពុលជាអ្វី ?

ការបំពុល គឺការធ្វើអោយកខ្វក់បរិស្ថានដោយសារសំណល់ផ្សេងៗ ដែលបានបោះចោលដោយប្រជាពលរដ្ឋ ។ ដូច្នេះបើសំណល់ ផ្សេងៗទាំងនោះ ត្រូវបានគេចោលមិនត្រឹមត្រូវបណ្តាលអោយមានការបំពុលបរិស្ថាន ។

ការបំពុលបរិស្ថានសំខាន់ ៗមានបីប្រភេទគឺ :

- ការបំពុលទឹក
- ការបំពុលដី
- និងការបំពុលខ្យល់

ប្រសិនបើប្រជាពលរដ្ឋបោះចោលសំណល់ផ្សេងៗរបស់គេមិនបានត្រឹមត្រូវល្អទេនោះ វាអាចធ្វើអោយប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដល់បរិស្ថាន នឹង សុខមាលភាពរបស់ប្រជាពលរដ្ឋ ។

បើសិនប្រជាពលរដ្ឋទាំងនោះបានបោះចោលសំណល់ផ្សេងៗទៅក្នុងស្ទឹង នោះទឹកស្ទឹងនឹងប្រែក្លាយទៅជាកខ្វក់ ហើយកាលណាប្រជាពលរដ្ឋ ប្រើប្រាស់ទឹកកខ្វក់នោះវានឹងនាំអោយមាន ជំងឺ ។

បើសិនប្រជាពលរដ្ឋចោលសំណល់ផ្សេងៗនៅតាមថ្នល់សត្វកណ្តុរដែលរុករកចំណីក្នុងសំណល់សំរាមទាំងនោះ វាបណ្តាលអោយចម្លងជម្ងឺដល់មនុស្ស ។

# កិច្ចការពារបរិស្ថានចំពោះការបំពុលដោយសំណល់ផ្សេងៗ

បច្ចេកទេសតទៅនេះ ប្រជាជនគ្រប់រូប អាចយកមកប្រើដើម្បីការពារការបំពុលបរិស្ថាន :

១ វិធីដ៏ប្រសើរដើម្បីកាត់បន្ថយបរិមាណសំណល់ផ្សេងៗគឺ យើងត្រូវកាត់បន្ថយការចោលសំណល់ផ្សេងៗ អោយបានបរិមាណ តិច តាំងពីកន្លែងដំបូងដែលយើងផលិតសំណល់ផ្សេងៗ ។

២ ការកែច្នៃ ឬ យកសំណល់ផ្សេងៗមកប្រើប្រាស់ឡើងវិញ ប្រសើរជាងការយកសំណល់ផ្សេងៗទៅកប់ក្នុងដីឬដុតចោល ។

៣ យើងគួរដុត ឬ កប់ចោលតែសំណល់ផ្សេងៗណាដែលយើងបានកែច្នៃ ឬ ប្រើប្រាស់ច្រើនលើករួចហើយ ។

៤ ការយកសំណល់កែវ និង ប្លាស្ទិក ដែលយើងមិនអាចកែច្នៃ ឬ ប្រើប្រាស់ឡើងវិញបាន ទៅកប់ចោលក្នុងដី ឬចោលនៅកន្លែង ចោលសំរាម ប្រសើរជាងការយកទៅដុតចោល ។

៥ មិនត្រូវចោលសំណល់ផ្សេងៗនៅលើថ្នល់ ឬ ក្នុងស្ទឹងឡើយ ។

## ការកាត់បន្ថយសំណល់ផ្សេងៗ

វិធីដ៏ប្រសើរបំផុត ដើម្បីការពារបរិស្ថាន ពីការបំពុល គឺត្រូវកាត់បន្ថយបរិមាណសំណល់ផ្សេងៗដែលយើងបានបោះចោល ។

ប្រជាពលរដ្ឋអាចកាត់បន្ថយបរិមាណសំណល់ផ្សេងៗបានយ៉ាងងាយដោយគ្រាន់តែការប្រុងប្រយ័ត្នចំពោះការទិញអីវ៉ាន់ ពីផ្សារប៉ុណ្ណោះ ។ ឧទាហរណ៍ ដូចជាពេលយើងទិញអីវ៉ាន់អ្វីមួយមកពីផ្សារ ដែលបានវេចខ្ចប់ក្នុងប្រអប់ក្រដាស ឬ ក្រដាស់ខ្ចប់រួចហើយ យើងមិនត្រូវដាក់វាក្នុងថង់ប្លាស្ទិកថែមទៀតទេ ។

របស់អ្វីមួយដែលសំគាល់ថាបានប្រើប្រាស់រួចម្តងហើយ ហៅថាផលិតផលដែលប្រើហើយអាចបោះចោលបាន ។ ប្រជាពលរដ្ឋ អាចកាត់បន្ថយបរិមាណសំណល់ផ្សេងៗទាំងនោះ តាមរយៈការមិនប្រើផលិតផលដែលប្រើហើយ អាចបោះចោលនោះទេ ។ ឧទាហរណ៍ ដូចជានៅពេលដែលយើងដើរលេងកំសាន្ត យើង អាចប្រើចានស្រាក់ ដាក់ចំណីអាហារជំនួសការប្រើប្រអប់ស្នោខ្ចប់បាយ ដែលបន្ទាប់ពីប្រើ រួចម្តងហើយ ត្រូវបោះចោលនោះទេ ។

## ការកែច្នៃ និង ការប្រើប្រាស់សំណល់ផ្សេងៗឡើងវិញ

សំណល់ផ្សេងៗដែលមនុស្សម្នាក់លែងត្រូវការ អាចមានប្រយោជន៍សំរាប់អ្នកម្នាក់ផ្សេងទៀតប្រើប្រាស់បន្ត ។ កាលណា សំណល់ផ្សេងៗទៅជាមានប្រយោជន៍សំរាប់មនុស្សម្នាក់ទៀតប្រើប្រាស់ ហៅថាសំណល់ផ្សេងៗកែច្នៃ ឬ អាចប្រើ ប្រាស់ឡើងវិញ ។ រោងចក្រជាច្រើនតែងចំណាយប្រាក់យ៉ាងច្រើន ក្នុងការនាំចូលសំភារៈចាំបាច់ពីប្រទេសដទៃ ដើម្បីធ្វើផលិតផលថ្មី ។ រោងចក្រមួយចំនួន កែច្នៃ និង ប្រើប្រាស់ សំណល់ផ្សេងៗ ដែលប្រជាពលរដ្ឋបោះចោលដើម្បីធ្វើផលិតផលសារជាថ្មី ជំនួសការនាំចូលនូវសំភារៈមានតំលៃខ្ពស់ ពីប្រទេសដទៃ ។

តទៅនេះ គឺជាបញ្ជីឈ្មោះសំណល់ផ្សេងៗ ដែលអាចកែច្នៃឡើងវិញ និង អាចអោយអ្នកផ្សេងទៀតយកទៅប្រើប្រាស់បាន មាន ៖

- សំភារៈធ្វើអំពីដែកថែប ដែកចម្មតា ទង់ដែង និង អាលុយមីនីញ៉ូម
- ក្រដាស និង ឡាំងក្រដាស
- ប្រេង
- ដបកែវ និង ដបប្លាស្ទិកមួយចំនួន

ជាញឹកញាប់យើងតែងយកសំណល់របស់យើងមកប្រើប្រាស់ជាថ្មីម្តងទៀត ឧទាហរណ៍ដូចជាយើងយកដបប្លាស្ទិកមកលាងសំអាត ហើយប្រើ ដាក់អ្វីៗជាច្រើនលើកបន្តទៀត រហូតលែងត្រូវការប្រើវា ទើបយកទៅបោះចោល ។ ឡាំងក្រដាស និង ថង់ប្លាស្ទិកមួយចំនួន ក៏យើងតែងយកវាមកប្រើប្រាស់ជាច្រើនលើកទៀត មុននឹងយកទៅបោះចោល ។

## តើប្លាស្ទិកជាអ្វី ?

ផ្លាស្ទិកជាផលិតផលគីមី ចំរាញ់ចេញពីប្រេង ឧស្ម័នធម្មជាតិ និង ធ្យូងថ្ម ។ ប្រេង ឧស្ម័នធម្មជាតិ និង ធ្យូងថ្ម ហៅថាធនធានធម្មជាតិដែលកើតឡើងនៅក្រោមដីអស់រយៈពេលជាច្រើនលានឆ្នាំ ។ ធនធានធម្មជាតិខ្លះ នៅពេលប្រើ វាអស់ វាមិនអាចកើតមានអ្វីទៀតជំនួសវិញទេ ។ ធនធានធម្មជាតិទាំងនោះហៅថា " ធនធានធម្មជាតិមិនអាចកើតឡើងវិញ " ។ ប្រេង និង ធ្យូងថ្ម ជាធនធានធម្មជាតិមិនអាចកើតឡើងវិញ ហើយគ្មានអ្នកណាមួយដឹងថាតើវានឹងប្រើអស់នៅពេលណាឡើយ ។

## តើវត្ថុវេចខ្ចប់ជាអ្វី ?

ប្លាស្ទិកភាគច្រើនគេផលិតដើម្បីប្រើសំរាប់ធ្វើជាវត្ថុវេចខ្ចប់ ។ វត្ថុវេចខ្ចប់ជាសំភារៈប្រើប្រាស់ដើម្បីរក្សាទុក ចំណីអាហារអោយនៅស្រស់ល្អ និង ការពាររបស់អ្វីៗដែលប្រជាពលរដ្ឋទិញ កុំអោយមានការខូចខាត ឧទាហរណ៍ដូចជា ដបប្លាស្ទិក និង ថង់ប្លាស្ទិកជាដើម ។ សំណល់សំរាមប្រហែលជា មួយភាគបី ជាសំណល់សំរាមផ្ទះសំបែងដែលបោះចោល ដោយសារប្រជាពលរដ្ឋ ។

## តើវត្ថុដែលប្រើប្រាស់ហើយ អាចបោះចោលជាអ្វី ?

កាលណាប្រជាពលរដ្ឋបានទិញអីវ៉ាន់ពីហាងឬពីផ្សារនាំយកមកផ្ទះ គាត់បានបោះចោលវត្ថុដែលវេចខ្ចប់អីវ៉ាន់នោះ ។ សំភារៈដូចជាវត្ថុវេចខ្ចប់ ដែលប្រជាពលរដ្ឋប្រើម្តងរួចហើយ បន្ទាប់មក គាត់បោះចោល ហៅថា វត្ថុដែលប្រើ ហើយអាចបោះចោល ។ វត្ថុវេចខ្ចប់ធ្វើអំពីជាតិប្លាស្ទិក បង្កើតអោយមានបញ្ហាធំៗ ព្រោះថា ៖

១ ជាវត្ថុដែលមិនអាចរលាយខូចផ្នែកជីវៈរបស់វា និង រលួយពុកផុយ ក្នុងរយៈពេលយូរអង្វែង ។

២ កាលណាគេដុតវាៗនឹងបញ្ចេញសារធាតុគីមីចូលក្នុងខ្យល់ បណ្តាលអោយមានការបំពុលខ្យល់ ។

## តើថង់ប្លាស្ទិកដែលបោះចោលរៀងរាល់ថ្ងៃមានចំនួនប៉ុន្មាន ?

ប្រទេសកម្ពុជាមានប្រជាជនចំនួនប្រហែល ១២ លាននាក់ ប្រសិនបើប្រជាជនទាំងអស់ បានប្រើប្រាស់ថង់ប្លាស្ទិកម្នាក់បួន ហើយបោះចោលរៀងរាល់ថ្ងៃនោះ បានសេចក្តីថា មានថង់ប្លាស្ទិកចំនួន ៤៨ លាន ត្រូវបានគេបោះចោលជារៀងរាល់ថ្ងៃ ។

# នេះជាចំនួនថង់ប្លាស្ទិកដ៏ច្រើន !

## តើសំណល់ផ្សេងៗជាអ្វី ?

សំណល់ផ្សេងៗគឺរបស់អ្វីៗដែលគេមិនត្រូវការ ឬ គ្មានប្រយោជន៍សំរាប់ប្រើធ្វើអ្វី ១ ថ្មីឡើងវិញកើតទៀត ។សំណល់អាចជាវត្ថុរឹង ( ដូចជាសំបកដប សំបកកំប៉ុង ) ជាវត្ថុរាវ ( ដូចជាទឹកសំអុយ ) ឬ ជាឧស្ម័ន ( ដូចជា ផ្សែងចេញ ពីរថយន្ត ) ។

## តើសំណល់ផ្សេងៗអាចរលាយខូចផ្ទៃកជីវៈរបស់វា ជាអ្វី ?

ក្នុងបរិស្ថានធម្មជាតិ មានសារធាតុសរីរាង្គ ល្អិតតូចៗ និង សត្វល្អិត ដែលអាចស៊ីសំណល់ផ្សេងៗ ដែល ប្រជាពលរដ្ឋបោះចោល ឧទាហរណ៍ ដូចជា យើងលាយច្របល់ ចំណីអាហារសេសសល់ ជាមួយក្រដាស ឬ ប្រអប់ក្រដាសរឹង និង ដី បន្ទាប់មក សារធាតុសរីរាង្គក្នុងដី នឹង ស៊ីសំណល់អាហារសេសសល់ទាំងនោះទាល់តែអស់រលីង ។

សំណល់ផ្សេងៗ ដែលអាចផុយរលួយដោយធម្មជាតិ ហៅថាសំណល់ផ្សេងៗអាចរលាយខូចផ្ទៃកជីវៈរបស់វា ។

## តើសំណល់ផ្សេងៗមិនអាចរលាយខូចផ្ទៃកជីវៈរបស់វាជាអ្វី ?

សំណល់ផ្សេងៗដែលមិនអាចស៊ីដោយសារធាតុ សរីរាង្គទាំងនោះ ហៅថាសំណល់ផ្សេងៗមិនអាចរលាយខូច ផ្ទៃកជីវៈរបស់វា ។ សំណល់ផ្សេងៗមិនអាចរលាយខូចផ្ទៃកជីវៈរបស់វា អាចពុកផុយរលួយខូច ដោយរយៈពេលយូរឆ្នាំ ជួនកាលអាចរហូតដល់រាប់ពាន់ឆ្នាំ ។

ឧទាហរណ៍ខាងក្រោមនេះបញ្ជាក់ពីចំនួន រយៈពេល ដែលសំណល់ផ្សេងៗមិនអាចរលាយខូចផ្ទៃកជីវៈរបស់វា ខ្លះៗអាចស្ថិតនៅក្នុងបរិស្ថាន មុននឹងពុកផុយរលួយខូច ៖

| | |
|---|---|
| ❖ កន្ទុយបារី ( កន្ទុយស្នោ ) | ពី ១ ទៅ ៥ ឆ្នាំ |
| ❖ កំប៉ុងអាលុយមីនីញ៉ូម | ពី ៨០ ទៅ ១០០ ឆ្នាំ |
| ❖ ថង់ប្លាស្ទិក | ពី ១០ ទៅ ២០ ឆ្នាំ |
| ❖ សំបកដប | ១លានឆ្នាំ |
| ❖ សំបកឡាំងធ្វើពីសំណប៉ាហាំង | ៥០ ឆ្នាំ |
| ❖ សំបកដបប្លាស្ទិក | មិនអាចកំណត់ |

## ការបោះចោលសំណល់ផ្សេងៗ

សំណល់ផ្សេងៗ បានបង្កឡើងដោយសកម្មភាពរបស់ប្រជាពលរដ្ឋ ហើយសំណល់ផ្សេងៗទាំងនោះ បានធ្វើអោយមានការ បំពុល ។ នៅពេលដែល ដី ទឹក ខ្យល់ ក្លាយទៅជាពុលដោយសារសំណល់ផ្សេងៗនោះ បរិស្ថានជុំវិញរបស់ប្រជាជនដែលកំពុងរស់នៅ និង ទៅជាមានគ្រោះថ្នាក់ និង ប៉ះពាល់ដល់សុខភាព ។ ប្រជាពលរដ្ឋទាំងអស់មានភារកិច្ចទទួលខុសត្រូវ ចំពោះការទុកដាក់សំណល់ ផ្សេងៗអោយបានត្រឹមត្រូវ ហើយធ្វើដូចនេះ គឺ ធ្វើអោយបរិស្ថានមានភាពល្អប្រសើរ សំរាប់ការរស់នៅរបស់ប្រជាពលរដ្ឋ ។

នៅប្រទេសកម្ពុជាមានមធ្យោបាយសំខាន់ៗពីរយ៉ាង ក្នុងការទុកដាក់សំណល់ផ្សេងៗគឺ :

១- កប់ចោលក្នុងដី

២- ការដុតចោល

## ការកប់សំណល់ផ្សេងៗក្នុងដី

នៅបណ្តាទីក្រុង និង ទីប្រជុំជនធំៗភាគច្រើន មានធ្វើរណ្តៅធំៗ សំរាប់ធ្វើជាកន្លែងបោះចោលសំណល់ ផ្សេងៗរបស់ប្រជាពលរដ្ឋ ។ ទីនោះហៅថាទីតាំងចោលសំណល់ផ្សេងៗ ។ ប្រជាពលរដ្ឋនៅតាមភូមិមួយចំនួន យកសំណល់ផ្សេងៗរបស់ពួកគេ ទៅតំបន់មួយ ហើយចាក់ចោលក្នុងរណ្តៅ ឬ នៅលើផ្ទៃដី ។ តំបន់នោះហៅ ជាកន្លែងចោលសំរាម ។

ជូនកាលអាចមានបញ្ហាជាច្រើន ចំពោះការចាក់ចោលសំណល់ផ្សេងៗនៅក្នុងដី ពិសេសនៅទីតាំង ចោលសំណល់ផ្សេងៗក្នុងទីក្រុង និង ទីប្រជុំជនធំៗ ។ នៅពេលណាសំណល់ផ្សេងៗដែលទុកចោល ក្នុងទីតាំងចោលសំណល់ផ្សេងៗ ប៉ះត្រូវទឹកភ្លៀង ទឹកប្រៃ ទៅជា កខ្វក់ ។ ប្រសិនបើទឹកកខ្វក់នោះជ្រាបចូលក្នុងដី អាចរលាយចូលក្នុងទឹកស្អាតក្រោមដី ដែលប្រជាពលរដ្ឋប្រើប្រាស់ ដងចេញ ពីអណ្តូង ។ ប្រសិនបើប្រជាពលរដ្ឋប្រើប្រាស់ទឹកអណ្តូងកខ្វក់ទាំងនោះ ពួកគេអាច និង មានជម្ងឺ ។ ទឹកក្រោមដីកខ្វក់ម្តងហើយ មិនអាចធ្វើអោយស្អាតឡើងវិញបានទេ ។

បញ្ហាជាច្រើនអាចកើតមានឡើងស្របគ្នា នៅពេលដែលទីតាំងចោលសំណល់ផ្សេងៗ និង កន្លែងសំរាប់ចោលសំរាម គ្រប់គ្រងមិនបានត្រឹមត្រូវល្អ ។ ក្នុងចំណោមបញ្ហាទាំងនោះមានបញ្ហា :

- ខ្លិនអាក្រក់
- ការរើកកាយដោយសត្វចង្រៃ
- និង ការពង្រាយសំរាមដោយខ្យល់បក់ ( សំណល់ផ្សេងៗដែលកប៉ិចរសាត់តាមខ្យល់គ្រប់ទិសទី )

## ការដុតសំណល់ផ្សេងៗ

នៅទីក្រុង និង ទីប្រជុំជនធំៗភាគច្រើន ទីតាំងសំរាប់ចោលសំណល់ផ្សេងៗ បានដំណើរការដោយក្រុមហ៊ុនឯកជន ។ ប្រសិនបើប្រជាពលរដ្ឋត្រូវការយកសំណល់ផ្សេងៗរបស់គេ ទៅចោលនៅទីតាំងសំរាប់ចោលសំណល់ផ្សេងៗ គេត្រូវតែជូលក្រុមហ៊ុន ឯកជន អោយ ប្រមូលសំណល់ផ្សេងៗទាំងនោះយកទៅបោះចោល ។ ជាទូទៅក្រុមហ៊ុនឯកជនច្រើនតែប្រមូលសំណល់ផ្សេងៗ ដែលមាន ភោជនីយដ្ឋាន ហាងលក់ដូរ និង ទីផ្សារ ប៉ុណ្ណោះ ។ ប្រជាពលរដ្ឋដែលមានសំណល់ផ្សេងៗមិនបានប្រមូលដោយក្រុមហ៊ុន ឯកជន ធ្លាប់តែដុតចោល នៅក្បែរៗលំនៅដ្ឋានរបស់ខ្លួន ។ ការដុតចោលសំណល់ផ្សេងៗ ក៏បណ្តាលអោយមានបញ្ហាដែរ ។

កាលណាប្រជាពលរដ្ឋដុតសំណល់ប្លាស្ទិក ឬ ស្បោពពុះកៅស៊ូ ឧស្ម័នបានបំភាយចេញទៅក្នុងបរិយាកាស និង ធ្វើអោយបរិយា- កាសកខ្វក់ដោយសារធាតុគីមី ហើយបណ្តាលអោយមានគ្រោះថ្នាក់តាមផ្លូវដកដង្ហើម ។ ពេលណាដែលភ្លើងឆេះសំណល់ផ្សេង ៗទាំងនោះ មិនគ្រប់គ្រាន់ វានឹងឆេះងំ ហើយបញ្ចេញផ្សែងខ្មៅចូលក្នុងបរិយាកាស ។ ផ្សែងខ្មៅរសាត់ចូលក្នុងបរិយាកាស បង្កើតបានជាភាគល្អិត តូចៗ រាប់លាន ដែលជួនកាលស្ថិតនៅក្នុងបរិយាកាសអស់រយៈពេលជាច្រើនម៉ោង ។

ជួនកាលសំណល់ផ្សេងៗខ្លះ មិនអាចឆេះរលាយខូចដោយសារភ្លើងបានទេ ឧទាហរណ៍ ដូចជា សំបកកំប៉ុង ដបកែវ ជាដើម ។ ប្រសិនបើលោហធាតុ និង អំបែងកែវដែលនៅសេសសល់លើដី បន្ទាប់ពីភ្លើងរលត់អស់ទៅនោះ ប្រជាពលរដ្ឋត្រូវវាយកំទេចរបស់ទាំង អស់នោះដោយខ្លួនយើងបន្ថែមផង ។ ការដុតសំបកកំប៉ុងខ្យល់អាអេរ៉ូសុល មានគ្រោះថ្នាក់ខ្លាំងណាស់ ។ សំបកកំប៉ុងទាំងនោះអាចផ្ទុះ នៅពេលភ្លើងឆេះ ហើយអាចធ្វើអោយរលាកភ្លើងដល់មនុស្សដែលនៅក្បែរ ។